មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

## នាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាទទួលបានដីកាកោះអញ្ជើញឱ្យចូលបង្ហាញខ្លួនក្នុងឋានៈជាសាក្សីក្នុងសំណុំរឿងលោក កឹម សុខា

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២

នៅព្រឹកព្រហាមថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២ អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») បានទទួលដីកាកោះពីសាលាដំបូងរាជធានីភ្នំពេញបង្គាប់ឱ្យអ្នកស្រីចូលបង្ហាញខ្លួនក្នុងឋានៈជាសាក្សីក្នុងសំណុំរឿងលោក កឹម សុខា អតីតមេដឹកនាំគណបក្សសង្គ្រោះជាតិ ដែលបច្ចុប្បន្នកំពុងស្ថិតក្រោមការចោទប្រកាន់ពី «សន្ធិដ្ឋិភាពជាមួយបរទេស» ក្រោមមាត្រា៤៤៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា។ យោងតាមដីកាកោះនោះ អ្នកស្រីត្រូវបានតម្រូវឱ្យចូលបង្ហាញខ្លួននៅក្នុងសវនាការនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២២ វេលាម៉ោង ៨.៣០នាទីព្រឹក នៅសាលាដំបូងរាជធានីភ្នំពេញ។

អ្នកស្រី ចក់ សុភាព បានបញ្ជាក់គោលជំហរថានឹងចូលបង្ហាញខ្លួនតាមដីកាកោះ។ ដើម្បីចូលបង្ហាញខ្លួនក្នុងឋានៈជាសាក្សី អ្នកស្រីត្រូវលុបចោលគម្រោងធ្វើដំណើរបំពេញបេសកកម្មទៅក្រៅប្រទេសដែលអ្នកស្រីត្រូវបានអញ្ជើញចូលរួមកម្មវិធីប្រជុំថ្នាក់តំបន់ ព្រមទាំងកម្មវិធីជួបពិគ្រោះយោបល់ផ្សេងៗជាច្រើនទៀតជាមួយអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិទទួលបន្ទុកសេរីភាពខាងការបញ្ចេញមតិនិងទស្សនយោបល់។ នេះគឺជាលើកទីពីរហើយដែលអ្នកស្រីត្រូវបានតុលាការកោះហៅពាក់ព័ន្ធក្នុងសំណុំរឿងលោក កឹម សុខា។ ក្នុងខែឧសភា ឆ្នាំ២០១៨ អ្នកស្រីត្រូវបានចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញបង្គាប់ឱ្យចូលខ្លួនដើម្បីសាកសួរក្នុងឋានៈជាសាក្សី ដែលនៅពេលនោះអ្នកស្រីបានចូលបង្ហាញខ្លួនតាមដីកាបង្គាប់។[1]

គួរកត់សម្គាល់ថា ម.ស.ម.ក ត្រូវបានបង្កើតឡើងក្នុងខែតុលា ឆ្នាំ២០០២ ដោយលោក កឹម សុខា ដែលជាអតីតសកម្មជនសិទ្ធិមនុស្សដ៏លេចធ្លោនាពេលនោះ។ នៅដើមឆ្នាំ២០០៧ លោក កឹម សុខា បានលាឈប់ពីអង្គការដើម្បីចូលរួមអាជីពនយោបាយ។ ចាប់តាំងពីលោកលាឈប់ពីការងារមក ម.ស.ម.ក បានផ្លាស់ប្តូរមេដឹកនាំចំនួនពីររូប ដោយអ្នកស្រី ចក់ សុភាព ត្រូវបានតែងតាំងជានាយិកាប្រតិបត្តិនៅក្នុងឆ្នាំ២០១៤។ តាំងពីដើមរហូតមក ម.ស.ម.ក ធ្វើសកម្មភាពផ្អែកតាមគោលការណ៍ក្នុងការលើកកម្ពស់និងការពារគុណតម្លៃ និងសិទ្ធិនានាមានចែងក្នុងរដ្ឋធម្មនុញ្ញកម្ពុជានិងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនានាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។ ម.ស.ម.ក តែងតែប្រកាន់ខ្ជាប់នូវគោលការណ៍ឯករាជ្យពីគណបក្សនយោបាយ និងអតីតបុគ្គលិក ក្នុងនោះរួមទាំងអតីតបុគ្គលិកដែលបានចូលប្រឡូកក្នុងនយោបាយផងដែរ។

---

[1] សេចក្តីថ្លែងការណ៍ ម.ស.ម.ក « នាយិការប្រតិបត្តិនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាទទួលបានដីកាកោះអញ្ជើញឱ្យចូលខ្លួនឆ្លើយបំភ្លឺជាសាក្សីក្នុងសំណុំរឿងលោក កឹម សុខា (ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨) https://bit.ly/2LaiTfw។

ម.ស.ម.ក មានការប្តេជ្ញាមោះមុតចំពោះសិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ព្រោះ ម.ស.ម.ក ធ្វើសកម្មភាពដើម្បីសម្រេចនូវចក្ខុវិស័យប្រទេសកម្ពុជាមានសន្តិភាព ស្របតាមកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស។ ខណៈនេះ ម.ស.ម.ក បានកំពុងរៀបចំកម្មវិធីប្រារព្ធខួប២០ឆ្នាំរបស់ខ្លួន ដែលជាព្រឹត្តិការណ៍ដ៏សំខាន់បង្ហាញនូវកិច្ចប្រឹងប្រែងក្នុងរយៈពេល២០កន្លងមកនេះក្នុងការដោះស្រាយបញ្ហាសិទ្ធិមនុស្ស ការគាំទ្រដល់ពលរដ្ឋនៅទូទាំងប្រទេសក្នុងការទាមទារសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់ខ្លួន ព្រមទាំងជួយជនរងគ្រោះពីការរំលោភបំពានសិទ្ធិមនុស្សក្នុងការទទួលបានយុត្តិធម៌ ដែលជាការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រកបដោយចីរភាពរបស់ប្រទេសកម្ពុជា។[2]

**អ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក មានប្រសាសន៍ថា៖**

*«ខ្ញុំនឹងចូលបង្ហាញខ្លួននៅចំពោះមុខតុលាការដើម្បីឆ្លើយសំណួរនានាតាមអ្វីដែលខ្ញុំបានដឹងដោយស្មោះត្រង់ទៅតាមលទ្ធភាពរបស់ខ្ញុំ។ ខ្ញុំក៏ស្នើឱ្យតុលាការពន្លឿននីតិវិធី និងធានាថាតុលាការគោរពតាមបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌អន្តរជាតិ និងគោរពពេញលេញនូវសិទ្ធិរបស់សាក្សី និងភាគីគ្រប់រូបក្នុងសំណុំរឿងនេះ»។*

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងអ្នកស្រី ចក់ សុភាព នាយិកាប្រតិបត្តិ ម.ស.ម.ក តាមរយៈ** chaksopheap@cchrcambodia.org **ឬទូរស័ព្ទ៖ (០) ១១ ៩៤៣ ២១៣។**

**-ចប់-**

**<u>បណ្ណាធិការ៖</u>**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្ស សម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS) ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អេស អូ អេស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រីសបេន ប្រទេសអូស្ត្រាលី៕

---

[2] សេចក្តីប្រកាសព័ត៌មាន «មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជានឹងប្រារព្ធខួប២០ឆ្នាំ» (ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០២២) https://bit.ly/3dR5wVR